# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបឯកឧត្តមអនុរដ្ឋមន្ត្រី
# ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម វៀតណាម






នៅរសៀលថ្ងៃទី០៧ ខែ មេសា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម បានទទួលជួបឯកឧត្តម **ង្វៀង កាមទី (Nguyen Cam Tu)** អនុរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម វៀតណាម ដើម្បីសំដែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួង ។






ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងបានលើកឡើងពីទំនាក់ទំនងដ៏ល្អរវាងកម្ពុជា–វៀតណាម លើវិស័យសេដ្ឋកិច្ច–ពាណិជ្ជកម្ម ទាំងក្របខ័ណ្ឌទ្វេភាគី និងអាស៊ាន ។ ទាក់ទង វិស័យឧស្សាហកម្ម ឯកឧត្តម ទេសរដ្ឋមន្ត្រី បាន ផ្តល់សារៈសំខាន់ទៅលើកិច្ចសហប្រតិបត្តិការ ទ្វេភាគី ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងចែករំលែកចំណេះដឹងលើវិស័យជាអាទិភាពមួយចំនួន ជាពិសេសកម្ពុជាចង់រៀនសូត្រពីវៀតណាម ទាក់ទងនិងការចងក្រងចង្កោមឧស្សាហកម្ម ីរសួនឧស្សាហកម្ម ដើម្បីឱ្យមានភាពប្រទាក់ក្រឡាគ្នា ដែលមានលក្ខណៈជាឧស្សាហកម្មគាំទ្រគ្នាទៅវិញទៅមក ។ កត្តានេះ វាជះឥទ្ធិពលដល់ការវិវឌ្ឍន៍រីកចម្រើនផ្នែកវិស័យសហគ្រាសធុនតូច និងមធ្យម ផងដែរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងពីការអនុម័តរបស់រាជរដ្ឋាភិបាល នាពេលថ្មីៗនេះក្នុងការបង្កើតគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ពី២០១៥-២០២៥ ក្នុងគោលដៅធ្វើយ៉ាងណាឱ្យវិស័យឧស្សាហកម្មកម្ពុជា មានចំណែកផលទុនជាតិសរុបលើសពីវិស័យកសិកម្ម ។ ក្នុងនោះបានកំណត់យកខេត្តព្រះសីហនុ ជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានជម្រាបថា បច្ចុប្បន្នកម្ពុជា មានរោងចក្រសរុបប្រមាណ ៥៦៣ រោងចក្រ ស្រូបកំលាំងពលកម្មបានចំនួនប្រមាណជិត៥ សែន នាក់ និងបើកប្រាក់បៀវត្សន៍ប្រចាំខែប្រមាណ២៨ លានដុល្លាអាមេរិក ។ ភាពរីកចម្រើនលើវិស័យនេះ ដោយសារកម្ពុជាទទួលភាពអនុគ្រោះពាណិជ្ជកម្មពីប្រទេសអភិវឌ្ឍន៍ និងប្រទេសដៃគូជាច្រើន ដែលអនុញ្ញាតឱ្យទំនិញនាំចេញពីកម្ពុជាមិនជាប់ពន្ធ និងមិនជាប់កូតា ។ ម៉្យាងកម្ពុជា ជាប្រទេសអភិវឌ្ឍន៍តិចតួចទី១ និងជាគំរូ ក្នុងការអនុវត្តរូបមន្តការធ្វើពាណិជ្ជកម្មផ្សារភ្ជាប់ និងលក្ខខ័ណ្ឌការងារ **(Link Trade with Labour Standard)** ដែលតម្រូវភាគីរោងចក្រត្រូវគោរពសិទ្ធកម្មករ និងលក្ខខ័ណ្ឌការងារជាចម្បង ដើម្បីមានសិទ្ធិនាំចេញផលិតផលរោងចក្ររបស់ខ្លួនទៅក្រៅប្រទេស ។

ឯកឧត្តម **Nguyen Cam Tu** អនុរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម វៀតណាម បានសម្តែងទឹកចិត្តរីករាយចំពោះជំនួបពិភាក្សានាថ្ងៃនេះ និងបានរំលឹកពីទំនាក់ទំនងដ៏ល្អរវាងឯកឧត្តមផ្ទាល់ និងឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ កាលឯកឧត្តមធ្វើជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការលើកកំពស់វិស័យពាណិជ្ជកម្ម ការដោះដូរទំនិញតាមព្រំដែន ក៏ដូចជាការបង្កើតទីផ្សារព្រំដែនជាដើម។ ឯកឧត្តម អនុរដ្ឋមន្ត្រីវៀតណាម បានវាយតម្លៃខ្ពស់ពីភាពរីកចម្រើនលើវិស័យឧស្សាហកម្មកម្ពុជា ហើយសង្ឃឹមថា គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា ពី ឆ្នាំ២០១៥-២០២៥ និងសម្រេចបានជោគជ័យតាមកាលកំណត់ ។ ជាមួយគ្នានេះភាគី វៀតណាមបានសម្តែងការពេញចិត្ត និងជម្រុញកិច្ចសហការល្អ ក្នុងការចែករំលែកបទពិសោធន៍ ចំណេះដឹង និងបច្ចេកវិទ្យា រវាងស្ថាប័នទាំងពីរ ក្នុងគោលដៅអភិវឌ្ឍន៍វិស័យឧស្សាហកម្មប្រកបដោយចិរភាព ។





